**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ០០២ គអ.អវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១១

**ជម្រាបជូន**

**លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ** : សំណើសុំសហការ និងផ្តល់ឯកសារពីប្រវត្តិតំបន់អន្លង់វែង ទីតាំងចុងក្រោយរបបខ្មែរក្រហម ។

**យោង** : - អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង របស់រាជរដ្ឋាភិបាល

- សេចក្តីសម្រេច លេខ ៤៨ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង របស់រាជរដ្ឋាភិបាល
- ស្មារតីអង្គប្រជុំគណៈកម្មការអន្តរក្រសួង ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ។

ដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជម្រាបជូនលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមេត្តាជ្រាបថា : គណៈកម្មការអន្តរក្រសួង មានគម្រោងរៀបចំ ទីតាំងដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ឲ្យទៅជាសារៈមន្ទីរមួយ ដើម្បីភ្ញៀវជាតិ និងអន្តរជាតិ បានឈ្វេងយល់រកការពិត ដើម្បីចងចាំ និងយុត្តិធម៌ សំរាប់សង្គមជាតិទាំងមូល ។ សូមលោកនាយក ជួយសហការរៀបចំលើផ្នែក ឯកសារ ពីប្រវត្តិ ស្រុកអន្លង់វែងដែលជាទីតាំងចុងក្រោយនៃរបបខ្មែរក្រហម ព្រមទាំងភស្តុតាងផ្សេងៗ និងរួមពិនិត្យមានយោបល់ លើប្រវត្តិទាំង១៤ចំណុច ដែលមានពង្រាងជូនជាប់ ដើម្បីចងក្រងជា Guide Book និងជាមេរៀនសម្រាប់ឧទ្ទេសនាមចំពោះមគ្គុទ្ទេសទេសចរណ៍ នៅតំបន់នោះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មេត្តា សហការផ្តល់ប្រវត្តិទាំងអស់ និងសូមជួយពិនិត្យលើប្រវត្តិ ១៤ចំណុច តាមការគួរ ។

សូម លោកនាយក មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ប្រធានគណៈកម្មការអន្តរក្រសួង**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**